**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលនៃកិច្ចប្រជុំថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១
## ដើម្បីដោះស្រាយវិវាទការងារនៅក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត

នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ នេះ ក្រសួងបានបន្តជួបសម្របសម្រួលដោះស្រាយករណីវិវាទការងារនៅក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត ដោយមានលោកស្រី ឈឹម ស៊ីថរ និង លោកមេធាវី ហាម ស៊ុនរិទ្ធិ ជាតំណាងភាគីកម្មករនិយោជិត និង លោក **Mike Ngai** ជាតំណាងភាគីក្រុមហ៊ុន។

ក្រោយពីការប្រជុំពិភាក្សា ភាគីទាំងពីរនៅតែមិនទាន់ព្រមព្រៀងក្នុងការបញ្ចប់ករណីវិវាទនៅឡើយ ដោយសារៈ

១-តំណាងក្រុមហ៊ុននឹងពិចារណាលើរូបមន្តក្នុងការគណនាប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារជូនបងប្អូនកម្មករនិយោជិតចំនួន ៨៥នាក់ ដែលបានឯកភាពទទួលយកការទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារស្របតាមច្បាប់ក្រោមការសម្របសម្រួលរបស់ក្រសួង ប៉ុន្តែ ក្រុមហ៊ុនមិនព្រមទទួលយកកម្មករនិយោជិតដែលកំពុងតវ៉ាផ្សេងទៀតឱ្យចូលធ្វើការវិញទេ។

២-តំណាងកម្មករនិយោជិតទាមទារឱ្យដោះស្រាយជាកញ្ចប់ ដោយតម្រូវឱ្យក្រុមហ៊ុនទទួលយកកម្មករនិយោជិតដែលកំពុងតវ៉ាឱ្យចូលធ្វើការជាមុន ទើបកម្មករនិយោជិតចំនួន ៨៥នាក់ផ្សេងទៀត ព្រមទទួលយកការទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារស្របតាមច្បាប់។

ក្រសួងសូមលើកទឹកចិត្តដល់បងប្អូនកម្មករនិយោជិត សហជីព ក៏ដូចជានិយោជក បន្តចូលរួមសហការជាមួយក្រសួង និងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីបញ្ចប់ករណីវិវាទនេះ ក្នុងស្មារតីយោគយល់គ្នាទៅវិញទៅមក។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមបងប្អូនកម្មករនិយោជិត និយោជក និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

*ថ្ងៃព្រហស្បតិ៍ ៥រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*

*រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១*